# មេរៀនទី ១៤៤៖ អេលីសេជួយស្ត្រីមេម៉ាយនិងកូនប្រុស របស់នាង

## ២ ពង្សាវតារក្សត្រ ៤៖១-៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/8M9RAwoJ8wg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/89oCIZGptrI

**គោលបំណង៖** ព្រះខ្វល់ខ្វាយចំពោះមនុស្សដែលមានសេចក្តីត្រូវការ។

**ខគម្ពីរចងចាំ៖ អេសាយ ៤១៖១៣** *"ដ្បិតអញនេះ គឺយេហូវ៉ាជាព្រះនៃឯង អញនឹងកាន់ដៃស្តាំឯង ដោយពោលនឹងឯងថា កុំឲ្យភ័យខ្លាចឡើយ អញនឹងជួយឯង ។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

២.ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

៣.ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត "ហុចតគ្នា"



សម្ភារៈដែលត្រូវការ៖ បាល់

១. ឲ្យកុមារគ្រប់គ្នាអង្គុយនៅលើកៅអីជារង្វង់ហើយបែរមុខចេញក្រៅ

២. ឲ្យបាល់ទៅកុមារណាម្នាក់

នៅពេលដែលគ្រូចាក់ភ្លេងកុមារត្រូវបញ្ជូនបាល់ទៅកុមារបន្តបន្ទាប់

៣. ប្រសិនបើកុមារណាម្នាក់កាន់បាល់នៅពេលភ្លេងឈប់

នោះកុមារនោះនឹងទទួលបានរង្វាន់ ហើយឈប់លេងល្បែងនេះ

៤. បន្តលេងល្បែងនេះរហូតដល់កុមារទទួលបានរង្វាន់គ្រប់ៗគ្នា

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កុមារគ្រប់ៗគ្នាសុទ្ធតែមានឱកាសទទួលបានបាល់ ហើយព្រះគឺយកចិត្តទុកដាក់ចំពោះយើងគ្រប់ៗគ្នា។

### ៤. ការណែនាំមេរៀន

រឿងមួយដែលមនុស្សទូទៅគ្រប់គ្នាមាននោះគឺសេចក្តីត្រូវការ។ ពួកយើងត្រូវការអាហារ ទឹក ផ្ទះ និងមនុស្សដែលបារម្ភពីយើង។ ដំណឹងល្អនោះគឺថា ព្រះគឺយកចិត្តទុកដាក់ចំពោះមនុស្សដែលត្រូវការ! ថ្ងៃនេះយើងនឹងរៀនអំពី របៀបដែលព្រះយកចិត្តទុកដាក់ចំពោះស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង នៅពេលដែលពួកគេមានសេចក្តីត្រូវការ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

អេលីសេគឺជា ហោរាដែលទទួលបានអំណាចរបស់អេលីយ៉ាទ្វេដង នៅពេលដែលព្រះបានលើកអេលីយ៉ាទៅឯនគរស្ថានសួគ៌ដោយរថជាភ្លើង។ គាត់បានបម្រើនៅឯភាគខាងជើងនៃរាជាណាចក្រអ៊ីស្រាអែល។ ថ្ងៃមួយមានស្ត្រីមេម៉ាយក្រីក្រម្នាក់បានមកឯអេលីសេ គឺជាម្នាក់ដែលប្ដីរបស់គាត់ធ្លាប់ធ្វើជាហោរា ហើយ

បានស្លាប់។ ប៉ុន្តែប្តីរបស់គាត់បានស្លាប់ដោយបន្សល់ទុកនូវបំណុលជាច្រើន ដែលគាត់មិនអាចសងគេអស់។ គាត់គឺមានកូនប្រុសពីរនាក់ ដែលម្ចាស់បំណុលបំរុងនឹងយកទៅធ្វើជាទាសករ រហូតដល់ពួកគេអាចសងបំណុលអស់!

នៅពេលដែលអេលីសេសួរនាងថា តើនាងមានអ្វីនៅក្នុងផ្ទះខ្លះ គាត់មានតែដបប្រេង១ប៉ុណ្ណោះ គាត់គឺពិតជាក្រីក្រខ្លាំងណាស់។ មនុស្សគឺប្រើប្រេងសម្រាប់ធ្វើអាហារ ប៉ុន្តែពួកគេក៏ប្រើសម្រាប់ស្បែក, ចង្កៀង និងធ្វើថ្នាំផងដែរ។ ដោយព្រោះតែគ្រប់គ្នាត្រូវការប្រេងនោះ ពេលខ្លះគេប្រើវាដូចជាលុយអីចឹង។ អេលីសេបានប្រាប់ទៅស្ត្រីមេម៉ាយនោះឲ្យប្រើកូនរបស់នាងទៅខ្ចីដបប្រេងទទេពីអ្នកជិតខាង។ ហើយគាត់បានប្រាប់ឲ្យខ្ចីឲ្យបានច្រើនតាមដែលអាចធ្វើបាន។

នៅពេលដែលពួកគេបានយកដបទាំងអស់មកហើយ អេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយនោះ ចាប់ផ្តើមចាក់ប្រេងបន្តិចដែលនាងមាន ចូលទៅក្នុងដបទាំងអស់ដែលកូនគាត់បានយកមកផ្ទះនោះ។ នេះគឺមិនសមហេតុផលទេសម្រាប់នាង ពីព្រោះថា តើគាត់អាចចាក់ប្រេងតែបន្តិចដែលគាត់មាន ឲ្យពេញដបដ៏ធំនោះបានយ៉ាងដូចម្តេច? ប៉ុន្តែនាងបានស្តាប់បង្គាប់ ព្រោះនាងបានដឹងថាអេលីសេគឺជាហោរារបស់ព្រះ។ ជាការអស្ចារ្យ គាត់អាចចាក់ប្រេងបំពេញដបទាំងអស់តាមរយៈប្រេងនៅក្នុងដបបន្តិចបន្តួចប៉ុណ្ណោះ! បន្ទាប់មកអេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយលក់ប្រេងដែលគាត់មាននោះ រួចសងបំណុលគេវិញ ហើយឲ្យពួកគេបន្តរស់នៅជាមួយប្រាក់ដែលនៅសេសសល់។

ស្ត្រីមេម៉ាយនិងកូនប្រុសទាំងពីររបស់គាត់ធ្លាប់គិតថា ស្ថានភាពរបស់ពួកគេគឺពិបាកខ្លាំងណាស់ និងមិនមានសង្ឃឹមទាល់តែសោះ។ ប៉ុន្តែព្រះបានប្រើអេលីសេមក នៅពេលដែលពួកគេមានសេចក្តីត្រូវការខ្លាំងបំផុត។ ព្រះស្រលាញ់មនុស្សគ្រប់គ្នា និងគ្រប់ទីកន្លែងទាំងអស់។ ប៉ុន្តែព្រះគឺយកចិត្តទុកដាក់ជាពិសេសសម្រាប់អ្នកដែលខ្វះខាត។ មនុស្សមួយចំនួនមានការស្រេកឃ្លាន។ ព្រះស្រលាញ់អស់អ្នកដែលស្រេកឃ្លាន។ មនុស្សមួយចំនួនមិនមានផ្ទះសម្បែងក្នុងការស្នាក់នៅ ហើយមិនមានក្រុមគ្រួសារដែលស្រលាញ់ពួកគេ។ ព្រះស្រលាញ់អស់អ្នកដែលគ្មានផ្ទះនិងគ្មានក្រុមគ្រួសារ។ ហើយព្រះគឺស្រលាញ់ដល់អ្នកដែលមានសេចក្តីត្រូវការគ្រប់ៗគ្នា។

សូមក្រឡេកមើលទៅមនុស្សដែលនៅជុំវិញអ្នក ហើយមើលពីអ្វីដែលពួកគេត្រូវការ។ ប្រហែលជាព្រះអាចប្រើអ្នកដូចជា ព្រះបានប្រើអេលីសេក្នុងការជួយពួកគេផងដែរ។ អ្នកអាចជួយដល់អ្នកដែលមានសេចក្តីត្រូវការនោះ តាមរយៈការចំណាយពេលវេលារបស់អ្នកជាមួយពួកគេ ឬតាមរយៈការដែលនិយាយពាក្យដែលបញ្ជាក់ថាអ្នកបារម្ភពីពួកគេ។ ឬក៏អ្នកអាចចែករំលែកនូវអ្វីដែលអ្នកមាន ដែលពួកគេកំពុងត្រូវការផងដែរ។ សូមចាំថា ព្រះយេស៊ូវគឺស្រលាញ់និងខ្វាយខ្វល់អស់អ្នកដែលមានសេចក្តីត្រូវការ!

## ៦. សំនួរពិភាក្សា

១. តើអ្នកបានដឹងអ្វីខ្លះអំពីអេលីសេ?

*(គាត់បានបម្រើនៅឯភាគខាងជើងនៃរាជាណាចក្រអ៊ីស្រាអែល គាត់ទទួលបានអំណាចរបស់អេលីយ៉ាទ្វេដង នៅពេលដែលព្រះបានលើកអេលីយ៉ា ទៅឯនគរស្ថាន ស្ចត់ដោយរថជាភ្លើង។)*

២. តើស្ត្រីមេម៉ាយមានបញ្ហាអ្វីបន្ទាប់ពីប្តីរបស់គាត់ស្លាប់ទៅ?

*(គាត់មិនអាចសងបំណុលអស់ ហើយកូន ប្រុសទាំងពីររបស់គាត់ជិតត្រូវគេចាប់យកទៅធ្វើជាទេសករ)*

៣. តើលោកអេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយនិងកូនប្រុសទាំងពីររបស់គាត់ធ្វើអ្វី?

*(ឲ្យទៅស្វែងរកដបទទេមកឲ្យបានច្រើន)*

៤. តើមានរឿងអ្វីកើតឡើងនៅពេលដែលស្ត្រីមេម៉ាយនោះបានចាក់ប្រេងបន្តិចដែលគាត់មានចូលទៅក្នុង

ដបធំទទេនោះ? *(គឺវាបានពេញគ្រប់ដប)*

៥. តើការនេះអាចកើតឡើងបានយ៉ាងដូចម្ដេច? *(វាអាចកើតឡើងបាន ដោយសារតែព្រះ ដែលពេញដោយព្រះចេស្ដា ហើយទ្រង់ខ្វាយខ្វល់ពីមនុស្សដែលមានសេចក្ដីត្រូវការ)*

៦. សូមគិតពីបុគ្គលដែលមានសេចក្ដីត្រូវការនៅជុំវិញ។ តើអ្នកអាចជួយគេបានដោយរបៀបណា? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ដ "ផ្លុំម្សៅ"**



សម្ភារៈដែលត្រូវការ៖ ម្សៅ តុ និងចាន

១. ចែកកុមារជា ២ក្រុម ហើយឲ្យពួកគេឈរជាជួរ

២. ដាក់ម្សៅក្នុងចាន ហើយដាក់វានៅលើតុ

៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទី១ពីក្រុមទាំង ២ ត្រូវរត់ទៅកាន់តុហើយផ្លុំម្សៅនៅក្នុងចាននោះម្ដងរួចរត់ត្រឡប់មកក្រោយវិញ

៤. កុមារបន្ទាប់ត្រូវរត់បន្តទៅកាន់តុ និងផ្លុំម្សៅម្ដងទៀត។ បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់ៗគ្នាបានផ្លុំម្សៅនោះគ្រប់ៗគ្នា។

៥. ក្រុមណាដែលអាចផ្លុំម្សៅអស់ពីចានបានមុនគេក្រុមនោះជាអ្នកឈ្នះ

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាគឺមិនអាចទៅរួចនោះទេដែលកុមារអាចផ្លុំម្សៅឲ្យអស់ពីចាននោះ។ ក៏ដូចគ្នានេះដែរ វាគឺគ្មានអ្វីដែលអាចបញ្ឈប់ព្រះមិនឲ្យយកចិត្តទុកដាក់ចិត្តចំពោះអ្នកបានឡើយ។ ព្រះគឺតែងតែយកចិត្តទុកដាក់អស់អ្នកដែលបានសេចក្ដីត្រូវការ។

**៨. ខគម្ពីរចងចាំ**

**អេសាយ ៤១៖១៣** *"ដ្បិតអញនេះ គឺយេហូវ៉ាជាព្រះនៃឯង អញនឹងកាន់ដៃស្តាំឯង ដោយពោលនឹងឯងថា កុំឲ្យភ័យខ្លាចឡើយ អញនឹងជួយឯង ។"*

**៩. ហត្ថកម្ម "អេលីសេជួយស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង" - ផាត់ពណ៌**

សូមព្រីនក្រដាសហត្ថកម្មសម្រាប់កុមារគ្រប់ៗគ្នា។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះយេស៊ូវបានបង្ហាញពួកយើងពីសេចក្ដីជំនឿដ៏រស់ពិតប្រាកដដែលមាននៅក្នុងយើង ថាមានលក្ខណៈយ៉ាងដូចម្ដេច។ ព្រះយេស៊ូវ និងព្រះគឺតែមួយហើយព្រះយេស៊ូវគឺដឹងប្រាកដថាទ្រង់អាចពឹងលើព្រះបានគ្រប់ពេល។ ហើយតាមរយៈការដែលយើងមានទំនាក់ទំនងជាមួយទ្រង់យើងក៏អាចរស់នៅក្នុងសេចក្ដីជំនឿបានដែរ។ ការដែលមានសេចក្ដីត្រូវការអាចនាំយើងឲ្យពឹងផ្អែកទៅលើព្រះបានកាន់តែខ្លាំង។ ក្នុងនាមជាគ្រូបង្រៀន អ្នកត្រូវតែពឹងផ្អែកទៅលើព្រះឲ្យជួយអ្នកក្នុងការបង្រៀនផងដែរ។ តើកន្លងមកព្រះបានជួយអ្នកក្នុងការបង្រៀនដូចម្ដេចខ្លះ? សូមទូលសុំព្រះឲ្យជួយ និងពឹងផ្អែកលើព្រះអង្គ។ ព្រះគឺរងចាំក្នុងការបង្ហាញអ្នកពីរបៀបដែលទ្រង់យកចិត្តទុកដាក់ពីសេចក្ដីត្រូវការរបស់អ្នក។

# “អេលីសេជួយស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង”



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________

______________________________

______________________________

______________________________

______________________________